# បណ្ណលេខ១ (ក): ការលើកកម្ពស់សកម្មភាពរស់នៅប្រចាំថ្ងៃ ដើម្បីត្រៀមខ្លួនចូលសាលារៀន
















**រំដួល**មានផលលំបាកក្នុងការដុសធ្មេញ ងូតទឹក និងស្លៀកសំលៀកបំពាក់ដោយខ្លួនឯង ដែលទាំងនេះជាសកម្មភាពរស់នៅប្រចាំថ្ងៃ។ **រំដួល**អាចប្រើប្រាស់បង្គន់ និងហូបអាហារដោយខ្លួនឯងដោយមានការជួយពីម្ដាយរបស់នាង។ ដោយមានការគាំទ្រដូចជាការប្រើប្រាស់រូបភាព ឫ និមិត្តសញ្ញា **រំដួល**អាចអនុវត្តសកម្មភាពរស់នៅប្រចាំថ្ងៃបាន។

2.Flashcard_Level2_Khmer_V6.indd 2 9/6/23 2:41 PM

# ព័ត៌មានបន្ថែម៖

កុមារអូទីស្សឹមមិនមានថមថយផ្នែកចលនាទេ (ទាក់ទងនឹងសាច់ដុំ) ហេតុនេះហើយគេអាចអនុវត្តសកម្មភាពរស់នៅប្រចាំថ្ងៃបានច្រើនបើប្រៀបធៀបទៅនឹងកុមារមានពិការភាពផ្នែកបញ្ញា។ ទោះជាយ៉ាងណាក៏ដោយ កុមារអូទីស្សឹមមានផលលំបាកយល់ពីលំដាប់លំដោយ ដូចជា តើសកម្មភាពណាត្រូវធ្វើមុន និងក្រោយ។ គេត្រូវការជំនួយដើម្បីយល់ពីលំដាប់លំដោយសកម្មភាពតាមរយៈរូបភាព។ ពួកគេមានការយល់តាមរយៈរូបភាពបានប្រសើរជាងពាក្យសំដី។

**សកម្មភាពរស់នៅប្រចាំថ្ងៃ អាចធ្វើការអប់រំបានតាមរយៈរូបភាពសាមញ្ញៗ៖**

- **ការងូតទឹក:** ដាក់រូបភាពតាមលំដាប់លំដោយដូចជា បើកទ្វារបន្ទប់ទឹក ប្រើបោយដើម្បីដងទឹក ហាលកន្សែងពោះគោ ។ល។ ធ្វើដូចនេះនឹងជួយក្មេងឲ្យងូតទឹកខ្លួនឯងបាន។
- **ស្លៀកសំលៀកបំពាក់:** កុមារអូទីស្សឹមមួយចំនួន អាចជួបការលំបាកមួយចំនួន ឧទាហរណ៍ ដូចជាបិទឡេវអាវ ហេតុនេះហើយគេត្រូវការជំនួយ។
- **ហូបអាហារ:** ទោះជាកុមារអូទីស្សឹមមានការលំបាកក្នុងការទំពារ ឬលេបអាហារ និងរើសចំណីក៏ដោយ តែនៅពេលដែលគេដល់អាយុត្រូវចូលសាលារៀន គេអាចជម្នះបានតាមរយៈការគាំទ្របានគ្រប់គ្រាន់។
- **ការប្រើប្រាស់បង្គន់:** កុមារអូទីស្សឹមជាទូទៅមិនសូវមានបញ្ហាជាមួយនឹងការប្រើប្រាស់បង្គន់ទេ ប៉ុន្តែមានការលំបាកជាមួយនឹងលំដាប់លំដោយនៃការប្រើប្រាស់។

*នៅក្នុងករណីរំដួល ម្តាយរបស់នាងបានបង្រៀននាងទាន់ពេល ដូចនេះហើយនាងមិនមានបញ្ហាលំបាកក្នុងការនោម ឬ ការបន្ទោរបង់ឡើយ។*

សហការផលិតដោយ

ក្រោមជំនួយឧបត្ថម្ភពី រដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធី ACCESS

2.Flashcard_Level2_Khmer_V6.indd 3 9/6/23 2:41 PM

# បណ្ណលេខ១(ខ): ការលើកកម្ពស់សកម្មភាពរស់នៅប្រចាំថ្ងៃ ដើម្បីត្រៀមខ្លួនចូលសាលារៀន



ម្ដាយរបស់នាង បង្ហាញរូបភាពច្រាសដុសធ្មេញ និងជំហានក្នុងការដុសធ្មេញ។ ម្ដាយនាងនិយាយថា "**នេះជាច្រាសដុសធ្មេញយើងប្រើវាសម្រាប់ដុសធ្មេញ**" បន្ទាប់មកម្ដាយនាងបានជួយនាង ដើម្បីដាក់ថ្នាំដុសធ្មេញ និងបង្ហាញពីរបៀបដុសធ្មេញ។ ឥឡូវនេះ **រំដួល** អាចដុសធ្មេញខ្លួនឯងបានជារៀងរាល់ថ្ងៃ។ ម្ដាយរំដួលដឹងថា វាត្រូវការពេលវេលា និងការអនុវត្តសម្រាប់**រំដួល** ដើម្បីរៀនអនុវត្តសកម្មភាព ឬជំនាញថ្មីៗ ហើយគាត់បានប្ដេជ្ញាចិត្តថា នឹងជួយកូន ដើម្បីសម្រេចបានតាមបំណងរបស់នាង។

# ព័ត៌មានបន្ថែម៖

ប្រសិនបើអ្នកមានផលលំបាកផលិតរូបភាពទាក់ទងនឹងការរស់នៅប្រចាំថ្ងៃ មានធនធានជាច្រើនដែលអ្នកអាចស្វែងរកបានតាមរយៈអ៊ីនធឺណិត។ អ្នកអាចពិភាក្សាគ្នាជាមួយគ្រូពេទ្យព្យាបាលដោយចលនារបស់អ្នក គ្រូពេទ្យ ឬអ្នកអប់រំពិសេស ឬអ្នកមានអាជីពការងារ នៅមជ្ឈមណ្ឌលសុខភាពផ្លូវចិត្តកុមារ ដើម្បីទទួលព័ត៌មានបន្ថែម និងការគាំទ្រ។

ប្រសិនបើមានការគាំទ្របានត្រឹមត្រូវ កុមារអូទីស្សឹមមានភាពងាយស្រួលក្នុងការរៀន និងមានភាពម្ចាស់ការ ដែលអាចឲ្យគេចូលរៀននៅសាលារៀនបាន។

**ដើម្បីធ្វើឲ្យកុមារអូទីស្សឹមរៀនអំពីសកម្មភាពរស់នៅប្រចាំថ្ងៃដោយមានភាពម្ចាស់ការខ្លួនឯងបាន៖**

- **បំបែកភារកិច្ចទៅជាជំហានតូចៗ៖** ធ្វើដូចនេះ កុំឲ្យមើលឃើញការងារដែលត្រូវធ្វើមានលក្ខណៈធំដុំ និងទទួលបានលទ្ធផលច្រើន។
- **ប្រើប្រាស់រូបភាពសម្រាប់ជាជំនួយ** ដែលមានលក្ខណៈសមស្រប ដែលអាចឲ្យកូនរបស់អ្នកយល់ពីលំដាប់នៃសកម្មភាព និងអ្វីដែលគេត្រូវធ្វើ។
- **សរសើរកូន (ការជំរុញមានលក្ខណៈវិជ្ជមាន)** នៅពេលដែលគេធ្វើអ្វីមួយដោយខ្លួនឯងបានជោគជ័យ។ ធ្វើដូចនេះដើម្បីឲ្យគេមានទំនុកចិត្តបន្តរៀន និងធ្វើបានល្អ។
- **ត្រូវមានភាពអំណត់ និងសមស្របជាមួយនឹងរូបភាព៖** ប្រសិនបើរូបភាពដែលបានប្រើមិនមានប្រសិទ្ធភាព ចូរធ្វើការកែសម្រួល ឬផ្លាស់ប្តូរការបង្ហាញរូបភាព តាមរយៈការពិភាក្សាគ្នាជាមួយនឹងលោកគ្រូ/អ្នកគ្រូព្យាបាលចលនារបស់អ្នក។

សហការផលិតដោយ

ក្រោមជំនួយឧបត្ថម្ភពី រដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធី ACCESS

# បណ្ណលេខ២ (ក): រំដួលទៅសាលារៀន- របៀបរៀន (កាលវិភាគរូបភាព)









ឪពុកម្ដាយ**រំដួល**បង្កើតកាលវិភាគដោយប្រើរូបភាព ដើម្បីជួយ**រំដួល**ឲ្យយល់ពីលំដាប់សកម្មភាព មុនពេលទៅសាលារៀន។ កាលវិភាគនោះបង្ហាញ**រំដួល**នូវអ្វីដែល**រំដួល**ត្រូវធ្វើជាជំហានៗមុនពេលទៅសាលារៀន។

- ឪពុករំដួលបង្កើតកាលវិភាគដោយប្រើរូបភាព ដើម្បីជួយ**រំដួល**អនុវត្តការងារ ដូចជាត្រូវរៀបចំខ្លួនរួចរាល់ដើម្បីទៅសាលារៀន។ របៀបធ្វើសកម្មភាពពីមួយទៅមួយ និងការធ្វើលំហាត់នៅផ្ទះ។

2.Flashcard_Level2_Khmer_V6.indd 6 9/6/23 2:41 PM

# ព័ត៌មានបន្ថែម៖

កាលវិភាគដោយប្រើរូបភាពគឺមានប្រយោជន៍សម្រាប់កុមារអូទីស្សឹម។ វាអាចជួយឲ្យកុមារយល់ពីអ្វីដែលកំពុងកើតមាន និងអ្វីដែលជាការរំពឹងទុករបស់ពួកគេ ដែលអាចកាត់បន្ថយបានការថប់បារម្ភណ៍ និងជួយបង្កើនសមត្ថភាពគេដើម្បីអនុវត្តសកម្មភាព។

វាមានសារៈសំខាន់ ដើម្បីជ្រើសរើសរូបភាពសមស្រប និងមានលក្ខណៈពាក់ពន្ធ័នៅពេល ដែលរៀបចំកាលវិភាគដោយប្រើរូបភាព៖

- ប្រើរូបភាព និងនិមិត្តសញ្ញា ដែលកូនរបស់អ្នកអាចយល់បាន
- ធ្វើកាលវិភាគងាយៗដែលក្មេងអាចយល់បាន

សហការផលិតដោយ

ក្រោមជំនួយឧបត្ថម្ភពី រដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធី ACCESS

# បណ្ណលេខ២(ខ): រំដួលទៅសាលារៀន - របៀបរៀន (កាលវិភាគរូបភាព)











- ឪពុករំដួលកំណត់ពីសកម្មភាព និងបង្កើតរូបភាពឬនិមិត្តសញ្ញាសម្រាប់កិច្ចការនីមួយៗ។ គាត់បង្ហាញរូបភាពឬនិមិត្តសញ្ញានៅលើក្តារខៀនក្នុងបន្ទប់របស់នាង។
- គាត់បានពន្យល់ពីអត្ថន័យនៃរូបភាពឬនិមិត្តសញ្ញានីមួយៗ។ កិច្ចការនេះបានជួយរំដួលឲ្យអនុវត្តតាមកាលវិភាគជាជំហានៗ។

# ព័ត៌មានបន្ថែម៖

- ប្រើភាសាច្បាស់ និងស្របជាមួយរូបភាព
- ដាក់កាលវិភាគនៅក្នុងកន្លែងដែលកូនរបស់អ្នកងាយមើលឃើញ ឧទាហរណ៍ក្នុងបន្ទប់ដេក ឬជិតតុអាហារពេលព្រឹក
- ធ្វើការកែសម្រួលកាលវិភាគជាមួយកូនរបស់អ្នកប្រសិនមិនច្បាស់
- មានការអត់ធ្មត់ និងត្រូវធ្វើជាទៀងទាត់
- វាមានសារៈសំខាន់ ដើម្បីផ្តល់ពេលវេលាគ្រប់គ្រាន់ដល់កូនរបស់អ្នក ដើម្បីជាទម្លាប់ក្នុងការប្រើប្រាស់កាលវិភាគ និងអនុវត្តតាមកាលវិភាគ។

*ដោយធ្វើតាមការណែនាំ ឪពុករបស់រំដួលបានបង្កើតកាលវិភាគដោយប្រើរូបភាព ដែលមានភាពងាយស្រួលសម្រាប់នាងអនុវត្តតាម ហើយវាមានប្រសិទ្ធភាព និងផលប្រយោជន៍ច្រើន។*

សហការផលិតដោយ

ក្រោមជំនួយឧបត្ថម្ភពី រដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធី ACCESS

# បណ្ណលេខ៣ (ក): ផែនការរៀនសម្រាប់បុគ្គលម្នាក់ៗ




ឪពុកម្ដាយរបស់រំដួលបានធ្វើការរួមគ្នាជាមួយគ្រូបង្រៀន និងអ្នកព្យាបាល (អ្នកអប់រំពិសេស និងអ្នកព្យាបាលការនិយាយ) បង្កើតផែនការអប់រំសម្រាប់ម្នាក់ៗ ដើម្បីជួយនាងឲ្យរៀនមានប្រសិទ្ធភាពនៅសាលារៀន។

2.Flashcard_Level2_Khmer_V6.indd 10 9/6/23 2:41 PM

# ព័ត៌មានបន្ថែម៖

អូទីស្សឹមគឺជាចង្កោមវិបល្លាសមួយ និងគ្មានបុគ្គលអូទីស្សឹមណាដូចគ្នានោះទេ។ កុមារអូទីស្សឹមម្នាក់ៗ គឺមានលក្ខណៈផ្សេងៗគ្នា និងមានរបៀបរៀនផ្សេងៗគ្នាដែរ។ ហេតុដូច្នេះហើយវាមានសារៈសំខាន់ដើម្បីបង្កើតផែនការរៀនសូត្រឲ្យស្របទៅតាមកម្រិតរបស់គាត់ ប្រយោជន៍ដើម្បីឲ្យគាត់ទទួលការអប់រំមួយតាមកម្រិតសមរម្យ ដែលពួកគេត្រូវការដើម្បីទទួលបានការជោគជ័យនៅសាលារៀន។

**នេះជាចំណុចមួយចំនួនដែលត្រូវគិតនៅពេលបង្កើតផែនការរៀនសូត្រសម្រាប់ម្នាក់ៗ៖**

- ផែនការរៀនសូត្រសម្រាប់ម្នាក់ៗ គឺអាស្រ័យទៅលើសមត្ថភាពរបស់កុមារម្នាក់ៗ
- ផែនការរៀនសូត្រសម្រាប់ម្នាក់ៗ គួរតែអាចធ្វើការវាស់វែង និងអាចសម្រេចបាន
- ផែនការរៀនសូត្រសម្រាប់ម្នាក់ៗ គួរត្រូវបានកែសម្រួល និងធ្វើបច្ចុប្បន្នភាពឲ្យបានទៀងទាត់
- ការចូលរួមដោយសកម្មរបស់ឪពុកម្តាយក្នុងការរៀបចំផែនការ នឹងជួយសម្របសម្រួលសកម្មភាពជួយបន្ថែមនៅផ្ទះ
- ផែនការរៀនសូត្រសម្រាប់ម្នាក់ៗ សម្រាប់កុមារអូទីស្សឹម គួរតែមានរូបភាពច្រើន និងបញ្ចូលការអប់រំ


សហការផលិតដោយ

ក្រោមជំនួយឧបត្ថម្ភពី រដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធី ACCESS


2.Flashcard_Level2_Khmer_V6.indd 11 9/6/23 2:41 PM

# បណ្ណលេខ៣(ខ): ផែនការរៀនសម្រាប់បុគ្គលម្នាក់ៗ




ឪពុកម្តាយរបស់**រំដួល** គ្រូបង្រៀន និងអ្នកព្យាបាល ពិនិត្យ និងកែសម្រួលផែនការអប់រំសម្រាប់ម្នាក់ៗជាញឹកញាប់ យ៉ាងហោចណាស់ ៦ខែម្តង ដើម្បីធានាថា ផែនការនោះនៅតែបំពេញតម្រូវការរបស់នាង។ ឪពុកម្តាយរបស់**រំដួល**បានដឹងថា ផែនការអប់រំសម្រាប់ម្នាក់ៗមានសារៈសំខាន់ជួយ**រំដួល**ឲ្យមានសមត្ថភាពក្នុងការរៀន ដែលនឹងជួយ**រំដួល**ខ្លួនឯងទទួលបានការអប់រំមួយដែលនាងត្រូវការ។

# ព័ត៌មានបន្ថែម៖

តាមរយៈការធ្វើការងាររួមគ្នារវាង ឪពុកម្ដាយ គ្រូបង្រៀន និងអ្នកព្យាបាល ការបង្កើតផែនការរៀនសូត្រសម្រាប់ម្នាក់ៗអាចជួយកុមារសម្រេចបានការសិក្សារបស់គេយ៉ាងពេញលេញ។

នេះជាព័ត៌មានមួយចំនួនសម្រាប់ឪពុកម្ដាយដែលមានកូនអូទីស្សឹមសម្រាប់ពិចារណានៅពេលបង្កើតផែនការរៀនសូត្រសម្រាប់ម្នាក់ៗជាមួយនឹងគ្រូបង្រៀន៖

- **ត្រូវរៀបចំទុកជាស្រេច៖** ប្រាប់ពីចំណុចខ្លាំង និងចំណុចខ្សោយកូនអ្នក ក៏ដូចជា តម្រូវការការសិក្សា និងសង្គមដល់គ្រូរបស់គេ។
- **ធ្វើជាអ្នកតស៊ូមតិ៖** លើកឡើងពីតម្រូវការរបស់កូនអ្នក និងត្រូវប្រាកដថាគេនឹងទទួលបាន។
- **ត្រូវមានភាពបត់បែន៖** ស្ម័គ្រចិត្តសម្របសម្រួលនិងធ្វើការជាមួយក្រុមរៀបចំផែនការដើម្បីបង្កើតផែនការដែលល្អបំផុតសម្រាប់កូនរបស់អ្នក
- **ត្រូវមានភាពជាវិជ្ជមាន៖** ចងចាំថា ផែនការអប់រំសម្រាប់ម្នាក់ៗ ជួយសម្រួលពីតម្រូវការសិក្សារបស់បុគ្គលម្នាក់ៗអាស្រ័យទៅលើសមត្ថភាពសិក្សា សក្ដានុពល និងចំណង់ចំណូលចិត្តរបស់កុមារ។

*ជាមួយនឹងការគាំទ្រត្រឹមត្រូវ កុមារអូទីស្សឹមអាចរៀនបានប្រសិទ្ធភាពដូចកុមារដទៃទៀតដែរនៅសាលារៀន។ ផែនការរៀនសូត្រសម្រាប់ម្នាក់ៗដើរតួនាទីសំខាន់ដើម្បីធានាថា កុមារទាំងអស់នេះទទួលការអប់រំដែលគេត្រូវការដើម្បីសម្រេចបាននូវសក្ដានុពលដ៏ពេញលេញរបស់គេ។*

សហការផលិតដោយ

ក្រោមជំនួយឧបត្ថម្ភពី រដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធី ACCESS

# បណ្ណលេខ៤(ក): សារៈសំខាន់នៃការចូលរួមរបស់ឪពុកម្ដាយ និងការគាំទ្រការងារសាលា








**រំដួល**ជាញឹកញាប់ជួបបញ្ហា ក្នុងការធ្វើលំហាត់នៅផ្ទះ។ ឪពុកម្ដាយ**រំដួល**បានជួបជាមួយគ្រូរបស់នាង ដែលគាត់ផ្ដល់ដំបូន្មាន ផែនការសិក្សារបស់នាងបន្ទាប់ពីរៀននៅសាលា។ ជារៀងរាល់ថ្ងៃបន្ទាប់ពីរៀននៅសាលា ឪពុកម្ដាយ**រំដួល**បានអង្គុយជាមួយនាង ដើម្បីមើលផែនការ និងសួរនាងអំពីមេរៀន។

# ព័ត៌មានបន្ថែម៖

រឿងរ៉ាវរបស់**វិជ្ជួល**បង្ហាញពីសារៈសំខាន់នៃការចូលរួមរបស់ឪពុកម្ដាយបន្ទាប់ពីការរៀននៅសាលា។ ដោយការចូលរួមយ៉ាងសកម្មជាមួយគ្រូ និងគ្រូពេទ្យព្យាបាលចលនា ឪពុកម្ដាយអាចជួយកូនឲ្យទទួលបានជោគជ័យនៅសាលារៀន។ វាមានសារៈសំខាន់នឹងចងចាំថា កុមារ អូទីស្សឹម គឺមានភាពខុសគ្នា អ្វីដែលអាចធ្វើបានសម្រាប់កុមារម្នាក់ អាចធ្វើមិនបានសម្រាប់កុមារម្នាក់ផ្សេងទៀត។ វាមានសារៈសំខាន់សម្រាប់ឪពុកម្ដាយស្វែងយល់អ្វីដែលល្អសម្រាប់កូន និងត្រូវឲ្យគេមានសកម្មភាពចូលរួម។

**នេះជាឧទាហរណ៍មួយចំនួន ដែលឪពុកម្ដាយអាចចូលរួមជាមួយនឹងការអប់រំកូនរបស់គេ៖**

- **និយាយជាមួយកូនអំពីការងារប្រចាំថ្ងៃរបស់គេ៖** ឪពុកម្ដាយអាចសួរកូនរបស់ពួកគាត់ពីអ្វីដែលគេបានរៀននៅសាលារៀន។ គេធ្វើអ្វីខ្លះប្រចាំថ្ងៃអ្វីដែលគេរីករាយនឹងធ្វើ និងអ្វីដែលមិនរីករាយជាមួយ។ ធ្វើដូចនេះដើម្បីឲ្យឪពុកម្ដាយមានភាពផ្សារភ្ជាប់ជាមួយនឹងកូនពួកគាត់ និងបានដឹងពីអ្វីដែលគេធ្វើប្រចាំថ្ងៃ និងចំណង់ចំណូលចិត្តកូនរបស់ពួកគាត់។

សហការផលិតដោយ

ក្រោមជំនួយឧបត្ថម្ភពី រដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធី ACCESS

# បណ្ណលេខ៤(ខ): សារៈសំខាន់នៃការចូលរួមរបស់ឪពុកម្តាយ និងការគាំទ្រការងារសាលា







យូរៗម្តងឪពុកម្តាយរបស់**រំដួល**បានធ្វើការកែប្រែផែនការ ដោយមានការពិគ្រោះយោបល់ជាមួយគ្រូរបស់នាង។ ឥឡូវនាងបានការផ្តោតយកចិត្តទុកដាក់ក្នុងការរៀនសូត្រច្រើន ពេលនៅក្នុងថ្នាក់ និងបានធ្វើលំហាត់ដែលគ្រូដាក់ឲ្យធ្វើនៅផ្ទះបានទៀងទាត់។

2.Flashcard_Level2_Khmer_V6.indd 16 9/6/23 2:41 PM

# ព័ត៌មានបន្ថែម៖

- **ជួយធ្វើកិច្ចការដែលគ្រូដាក់ឲ្យធ្វើនៅផ្ទះ៖** ផ្ដល់កន្លែងស្ងាត់សម្រាប់ធ្វើការងារ បែងចែកការងារជាចំណែកតូចៗ និងផ្ដល់ភាពរីករាយចំពោះអ្វីដែលគេបានធ្វើ (ការជំរុញទឹកចិត្តវិជ្ជមាន) អាចធ្វើ ឲ្យកូនអ្នកបញ្ចប់កិច្ចការដែលគ្រូដាក់ឲ្យធ្វើនៅផ្ទះ។
- **ចូលរួមកិច្ចប្រជុំរវាងឪពុកម្ដាយ និងគ្រូ៖** វាមានសារៈសំខាន់ក្នុងការចូលរួមកិច្ចប្រជុំរវាងឪពុកម្ដាយ និងគ្រូ ដើម្បីសិក្សាពីការរីកចម្រើនរបស់ក្មេង និងពិភាក្សាពីការព្រួយបារម្ភដែលគេអាចជួបប្រទះ។ ធ្វើដូចនេះដើម្បីឲ្យឪពុកម្ដាយនៅតែបានចូលរួមជាមួយនឹងការអប់រំកូនរបស់ពួកគេ និងធានាបានការជោគជ័យចំពោះការសិក្សា។
- **ចូលរួមក្នុងសកម្មភាពរបស់សាលា៖** ការចូលរួមរបស់ឪពុកម្ដាយក្នុងសកម្មភាពរបស់សាលា និងការលើកទឹកចិត្តកូនឲ្យចូលរួមក្នុងសកម្មភាពចុះទៅទស្សនានៅកន្លែងផ្សេងៗ នឹងអាចឲ្យគេស្គាល់មិត្តរួមថ្នាក់ និងមិត្តភក្តិ។ ធ្វើដូចនេះដើម្បីឲ្យកុមារអូទីស្សឹមមានភាពប្រសើរឡើងចំពោះទំនាក់ទំនងមនោសញ្ចេតនាក្នុងសង្គម។

*ដោយការចូលរួមយ៉ាងសកម្មក្នុងការលើកកម្ពស់ផែនការអប់រំសម្រាប់ម្នាក់ៗ ឪពុកម្ដាយអាចលើកកម្ពស់ការរៀនសូត្រ និងជួយកូនរបស់គេជ្រើសរើសវគ្គបណ្ដុះបណ្ដាលអាជីពការងារ ដែលនឹងជួយគេឲ្យរស់នៅដោយមានភាពម្ចាស់ការ។*

សហការផលិតដោយ

ក្រោមជំនួយឧបត្ថម្ភពី រដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធី ACCESS

2.Flashcard_Level2_Khmer_V6.indd 17 9/6/23 2:41 PM

# បណ្ណលេខ៥(ក): ការលើកកម្ពស់ការទំនាក់ទំនងសង្គម នៅក្នុងសាលារៀន
















**រំដួល**ជួបបញ្ហាលំបាកក្នុងការបង្កើតមិត្តភក្តិ។ ឪពុកម្តាយរបស់នាងប្រើប្រាស់រូបភាព ឬនិមិត្តសញ្ញាដើម្បីជាជំនួយ និងជួយ**រំដួល**ដឹងពីអារម្មណ៍អ្នកដទៃ និងអ្វីដែលបាននឹងកំពុងនិយាយ និងធ្វើការឆ្លើយតបបានត្រឹមត្រូវ។ ខាងក្រោមនេះជាវិធីសាស្ត្រដែលបានជួយ**រំដួល**ចូលរួមសកម្មភាពជាមួយមិត្តភក្តិ និងបង្កើតមិត្តភក្តិ។

- ឪពុកម្តាយរបស់**រំដួល** សរសេរពីការរំភើបចិត្តផ្សេងៗ និងរូបភាពពាក់ពន្ធ័នៅលើបណ្ណ/ក្រដាស់ផ្សេងៗដើម្បីធ្វើឲ្យនាងយល់ពីអារម្មណ៍របស់អ្នកដទៃ។

2.Flashcard_Level2_Khmer_V6.indd 18 9/6/23 2:41 PM

# ព័ត៌មានបន្ថែម៖

**រំដួល**គឺជាឧទាហរណ៍មួយ អំពីការជួយកុមារអូទីស្សឹមអោយរៀនបង្កើនជំនាញទំនាក់ទំនងសង្គមរបស់គេ។ ជាមួយនឹងការគាំទ្រ និងយល់ដឹងបានត្រឹមត្រូវ  កុមារអូទីស្សឹមអាចរៀន ដើម្បីទំនាក់ទំនងជាមួយមិត្តភក្តិនៅសាលារៀន។

**នេះជាចំណុចមួយចំនួននៃការប្រាស្រ័យទាក់ទងដែលកុមារអូទីស្សឹមអាចត្រូវការឲ្យជួយ៖**

- ការទំនាក់ទំនងតាមក្រសែភ្នែក
- ការប្តូរវេនគ្នា
- ការធ្វើតាមការណែនាំ
- ការបង្ហាញពីអារម្មណ៍
- ការយល់ពីការប្រាស្រ័យទាក់ទងតាមរយៈកាយវិការ


សហការផលិតដោយ

ក្រោមជំនួយឧបត្ថម្ភពី រដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធី ACCESS



2.Flashcard_Level2_Khmer_V6.indd 19

9/6/23 2:41 PM

# បណ្ណលេខ៥(ខ): ការលើកកម្ពស់ការទំនាក់ទំនងសង្គម នៅក្នុងសាលារៀន



- ពួកគាត់ប្រើប្រាស់ភាសាច្បាស់ៗ និងសាមញ្ញ។
- ពួកគាត់ផ្តល់ពេលវេលាដល់រំដួល ដើម្បីអនុវត្ត និងធ្វើការឆ្លើយតបត្រឹមត្រូវយល់ពីអារម្មណ៍របស់អ្នកដទៃ (ពាក្យពេចន៍បង្ហាញពីអារម្មណ៍ ដូចជា ការខឹង និង ការសប្បាយចិត្តជាដើម)។
- ឪពុកម្តាយរបស់**រំដួល**មានភាពអំណត់ និងការយោគយល់ត្រូវដឹងថា **រំដួល**ឆ្លើយតបមិនបានត្រឹមត្រូវ។ មិនមែនដោយសារកំហុសរបស់នាង ប៉ុន្តែវាដោយសារសមត្ថភាពរបស់នាងមិនអាចដឹងពីអារម្មណ៍របស់អ្នកដទៃ។
- ឪពុកម្តាយរបស់**រំដួល** ឆ្លើយតបដោយត្រឹមត្រូវ និងសរសើរនាង (ការជំរុញបែបវិជ្ជមាន)។

# ព័ត៌មានបន្ថែម៖

ប្រសិនបើកូនរបស់អ្នកមានបញ្ហាដូចខាងលើទាក់ទងទៅនឹងការទំនាក់ទំនងសង្គម អ្នកអាចរៀបចំការជួយតាមរយៈរូបភាព ដែលមានលក្ខណៈជាក់លាក់ទៅតាមចំណុចនីមួយៗខាងលើដើម្បីជួយកូនរបស់អ្នក។ អ្នកអាចស្វែងរកជំនួយពីអ្នកព្យាបាលកូនរបស់អ្នក ឬក៏បុគ្គលិកអាជីព (ដូចជាគ្រូអប់រំពិសេស អ្នកព្យាបាលតាមរយៈសិល្បៈ និងអ្នកព្យាបាលការនិយាយ) ដើម្បីផលិតសម្ភារៈសម្រាប់បង្រៀនកូនរបស់អ្នក។ ជាមួយនឹងកាប្រើប្រាស់រូបភាពបានត្រឹមត្រូវ កុមារអូទីស្សឹមអាចត្រូវបានជួយនៅសាលារៀន ដើម្បីបង្កើនជំនាញទំនាក់ទំនងសង្គមរបស់គេ និងបង្កើតទំនាក់ទំនងជាមួយអ្នកដទៃ។

**នេះជាព័ត៌មានបន្ថែមមួយចំនួន ដើម្បីលើកកម្ពស់ការទំនាក់ទំនងសង្គមរបស់កុមារអូទីស្សឹម៖**

- ចាប់ផ្ដើមកត់ត្រាពីចំណុចខ្លាំង និងចំណុចខ្សោយរបស់កូនអ្នក និងចែករំលែកជាមួយគ្រូ។
- កំណត់ទិសដៅជាក់លាក់សម្រាប់ការអភិវឌ្ឍការទំនាក់ទំនងសង្គមរបស់កូនអ្នក ដោយមានការពិគ្រោះយោបល់ជាមួយគ្រូ។
- ផ្ដល់ឱកាសដល់កូនអ្នក ដើម្បីអនុវត្តជំនាញទំនាក់ទំនងសង្គម នៅក្នុងបរិយាកាសគាំទ្រដោយសុវត្ថិភាព។
- ប្រើប្រាស់រូបភាពដើម្បីជាជំនួយ ដើម្បីជួយកូនអ្នកឲ្យយល់ពីសញ្ញាប្រើប្រាស់ក្នុងសង្គម និងការការរំពឹងទុកផ្សេងៗ។
- ត្រូវមានភាពអំណត់និងសមស្របជាមួយនឹងការរីកចម្រើនរបស់កូនអ្នកទាក់ទងនឹងអ្នកដទៃ។
- អបអរជាមួយនឹងជោគជ័យរបស់កូនអ្នក បើទោះជាមានភាពលូតលាស់តិចតួច និងក្នុងជំហានដំបូង។

*វាមានសារៈសំខាន់នឹងចងចាំថា កុមារអូទីស្សឹមគឺមានភាពខុសគ្នា អ្វីដែលអាចធ្វើបានសម្រាប់កុមារម្នាក់ អាចធ្វើមិនបានសម្រាប់កុមារម្នាក់ផ្សេងទៀត។ វាមានសារៈសំខាន់ដើម្បីធ្វើការជាមួយកូនរបស់អ្នក ដើម្បីស្វែងរកវិធីសាស្ត្រល្អបំផុតសម្រាប់គេ។*

សហការផលិតដោយ

ក្រោមជំនួយឧបត្ថម្ភពី រដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធី ACCESS

# បណ្ណលេខ៦(ក): បញ្ហាអាកប្បកិរិយានៅក្នុងថ្នាក់រៀន






**រំដួល**រំខានដោយសំឡេងនៅជុំវិញ ហើយនាងបិទត្រចៀកទាំងពីររបស់នាង។ **សុភី**ដែលជាមិត្តភក្តិរបស់នាងបានសង្កេតឃើញអាកប្បកិរិយានេះ ហើយនាងបានទៅប្រាប់គ្រូប្រចាំថ្នាក់របស់នាង។ **សុភី** បាននាំ**រំដួល**ទៅកន្លែងស្ងាត់មួយ ដើម្បីឲ្យនាងបានស្ងប់ស្ងាត់។ គ្រូប្រចាំថ្នាក់បានឲ្យ**រំដួល**នូវពេលវេលាសម្រាកជាប្រចាំ ដើម្បីជួយឱ្យនាងមានអារម្មណ៍ស្ងប់ និងផ្ចង់យកចិត្តទុកដាក់ឡើងវិញ។

2.Flashcard_Level2_Khmer_V6.indd 22 9/6/23 2:41 PM

# ព័ត៌មានបន្ថែម៖

**ខាងក្រោមនេះជាបញ្ហាអាកប្បកិរិយាមួយចំនួន ដែលកុមារអូទីស្សឹម អាចមាននៅសាលារៀន៖**

- **អាកប្បកិរិយារំខានៈ** និយាយមិនចាំវេន បង្កសំឡេង យកសៀវភៅ/សម្ភារៈរបស់អ្នកដទៃ និងវាយបំបែករបស់ផ្សេងៗ ដើម្បីរំខានអ្នកដទៃ។
- **អាកប្បកិរិយាឆេវឆាវៈ** នេះអាចរាប់បញ្ចូលទាំងការវាយ ទាត់ និងខាំ ដោយគ្មានហេតុផល និងមិនសមហេតុផល។
- **ការដកខ្លួនចេញៈ** ការជៀសវាង គេចវេះ មិនឆ្លើយឆ្លងជាមួយអ្នកដទៃ មិននិយាយស្ដី មិនចូលរួមក្នុងសកម្មភាព និងនៅម្នាក់ឯង គឺជាអាកប្បកិរិយាកើតច្រើនក្នុងចំណោមកុមារដែលមានអូទីស្សឹម។


សហការផលិតដោយ

ក្រោមជំនួយឧបត្ថម្ភពី រដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធី ACCESS

# បណ្ណលេខ៦(ខ): បញ្ហាអាកប្បកិរិយានៅក្នុងថ្នាក់រៀន









នៅពេល**រំដួល**ត្រលប់មកប្រក្រតីឡើងវិញ គ្រូរបស់នាងក៏សរសើរនាង(ការជំរុញបែបវិជ្ជមាន) ដែលឱ្យ**រំដួល**យល់ថា អាកប្បកិរិយាល្អ គឺត្រូវបានគេលើកទឹកចិត្ត។ **សុភី** និងអ្នកគ្រូបានជួយ**រំដួល**ឲ្យរៀនគ្រប់គ្រងអាកប្បកិរិយារបស់នាង និងធ្វើឲ្យនាងអាចផ្ចង់យកចិត្តលើការងាររបស់នាងបានយ៉ាងល្អប្រសើរឡើងវិញ។

2.Flashcard_Level2_Khmer_V6.indd 24 9/6/23 2:41 PM

# ព័ត៌មានបន្ថែម៖

ប្រសិនបើកូនរបស់អ្នកកំពុងមានបញ្ហាអាកប្បកិរិយា អ្នកត្រូវនិយាយជាមួយមិត្តភក្តិរបស់គេ គ្រូបង្រៀន អ្នកចិត្តវិទ្យាប្រចាំសាលា និងបុគ្គលិកសង្គម។ ពួកគេអាចវាយតម្លៃអាកប្បកិរិយារបស់កូនអ្នក និងបង្កើតផែនការ ដើម្បីដោះស្រាយវា។

**មានយុទ្ធសាស្រ្តជាច្រើន ដែលអាចប្រើ ដើម្បីគ្រប់គ្រងបញ្ហាអាកប្បកិរិយាកុមារ ដែលមានអូទីស្សឹម ដូចជា៖**

- **ការជំរុញបែបវិជ្ជមានៈ** ផ្តល់រង្វាន់ដល់កូនរបស់អ្នក ដែលមានអាកប្បកិរិយាល្អ។
- **ដកចេញសិនៈ** ដកកូនរបស់អ្នកចេញពីស្ថានភាពមួយរយៈពេលខ្លី នៅពេលដែលពួកគេរំខានដល់អ្នកដទៃនៅក្នុងថ្នាក់រៀន។
- **ប្រើកាលវិភាគដោយមានរូបភាពៈ** វិធីនេះអាចជួយកូនរបស់អ្នក ឱ្យយល់ពីអារម្មណ៍របស់អ្នកដទៃ និងអ្វីដែលគេរំពឹងទុក និងមានអាកប្បកិរិយាស្របតាមបរិបទ។
- **និទានរឿងសង្គមៈ** វិធីនេះអាចជួយកូនរបស់អ្នករៀនអំពីស្ថានភាពសង្គម និងរបៀបឆ្លើយឆ្លងឱ្យបានត្រឹមត្រូវ។
- **ការព្យាបាលមុខងារប្រចាំថ្ងៃៈ** អ្នកព្យាបាលមុខងារប្រចាំថ្ងៃនឹងធ្វើការវាយតម្លៃលម្អិតអំពីបញ្ហាញ្ញាណដឹង និងរៀបចំផែនការព្យាបាលសមស្រប ដើម្បីបង្កើនជំនាញដោះស្រាយរបស់ពួកគេទាក់ទងនឹងបញ្ហាញ្ញាណដឹង។

*ប្រសិនបើកូនរបស់អ្នកកំពុងមានពីបញ្ហាអាកប្បកិរិយា សូមចងចាំថា មិនមែនមានតែកូនរបស់អ្នកទេដែលជួបរឿងបែបនេះ។ កុមារអូទីស្សឹមជាច្រើន តែងមានបញ្ហាអាកប្បកិរិយានៅដំណាក់កាលផ្សេងៗគ្នានៃការអភិវឌ្ឍរបស់ពួកគេ។ ប្រសិនបើមានការគាំទ្រត្រឹមត្រូវពីអ្នកចិត្តវិទ្យា និងគ្រូនៅសាលារៀន កូនរបស់អ្នកអាចគ្រប់គ្រងអាកប្បកិរិយារបស់ពួកគេ និងបន្តរៀនបានជាធម្មតា។*

សហការផលិតដោយ

ក្រោមជំនួយឧបត្ថម្ភពី រដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធី ACCESS

Australian Aid

ACCESS Sustainable quality services for all

2.Flashcard_Level2_Khmer_V6.indd 25 9/6/23 2:41 PM

# បណ្ណលេខ៧(ក)៖ ប្រភេទបញ្ហារួមផ្សំ







កាលរៀននៅសាលាមេត្តេយ្យ **រំដួល**ធ្លាប់ជាក្មេងមិនអាចអង្គុយ មិនសូវចាប់អារម្មណ៍របស់លេង និងមានបញ្ហាក្នុងការផ្ចង់អារម្មណ៍។ នាងត្រូវបានធ្វើរោគវិនិច្ឆ័យរកឃើញថាមានអូទីស៊ឹម។ អ្នកចិត្តវិទ្យាបានរៀបចំផែនការកញ្ចប់អន្តរាគមន៍ដ៏ទូលំទូលាយមួយសម្រាប់នាង ដែលបង្ហាញថានាងអាចអភិវឌ្ឍល្អប្រសើរ។ ឪពុកម្តាយរបស់នាងបានអនុវត្តយុទ្ធសាស្ត្រនៅផ្ទះ ដើម្បីជួយធ្វើឲ្យនាងបានស្ងប់ស្ងាត់។

2.Flashcard_Level2_Khmer_V6.indd 26 9/6/23 2:41 PM

# ព័ត៌មានបន្ថែម៖

ប្រសិនបើមានការគាំទ្រត្រឹមត្រូវពីឪពុកម្តាយ និងអ្នកចិត្តវិទ្យា កុមារអូទីស្សឹមអាចយកឈ្នះលើបញ្ហាប្រឈមផ្នែកសុខភាព (បញ្ហារួមផ្សំផ្សេងៗ) បាន ហើយអាចបន្តរៀននៅសាលាផងដែរ។

**បញ្ហារួមផ្សំមួយចំនួនក្នុងចំណោមកុមារអូទីស្សឹម មានដូចជា៖**

- **ការថប់បារម្ភ:** កុមារអូទីស្សឹមអាចជួបប្រទះការថប់បារម្ភក្នុងស្ថានភាពផ្សេងៗគ្នា ដូចជាស្ថានភាពសង្គម បរិយាកាសថ្មី ឬការផ្លាស់ប្តូរស្ថានភាព។
- **បញ្ហាធ្លាក់ទឹកចិត្ត:** កុមារអូទីស្សឹមអាចជួបប្រទះនឹងជំងឺធ្លាក់ទឹកចិត្ត ដែលអាចបង្ហាញជាភាពសោកសៅ ឆាប់ខឹង បាត់បង់ចំណាប់អារម្មណ៍ក្នុងសកម្មភាព ការផ្លាស់ប្តូរនៃការគេង និងចំណង់អាហារ ដែលច្រើនតែកើតមានក្នុងចំណោមមនុស្សវ័យជំទង់។
- **បញ្ហារពឹស ឬពិបាកផ្ចង់អារម្មណ៍ (ADHD):** កុមារអូទីស្សឹមក៏អាចមានបញ្ហារពឹស ឬពិបាកផ្ចង់អារម្មណ៍ (ADHD) នៅពេលដែលពួកគេពិបាកក្នុងការយកចិត្តទុកដាក់ ពិបាកគ្រប់គ្រងសន្ទុះចិត្ត និងពិបាកអង្គុយនៅស្ងៀមណាស់។

សហការផលិតដោយ

ក្រោមជំនួយឧបត្ថម្ភពី រដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធី ACCESS

Australian Aid

ACCESS Sustainable quality services for all

# បណ្ណលេខ៧(ខ): ប្រភេទបញ្ហារួមផ្សំ







កាលពីរៀនថ្នាក់ទី៦វិញ**រំដួល**ធ្លាប់មានបញ្ហាចលនានិងបានដួល។ នាងត្រូវបានធ្វើរោគវិនិច្ឆ័យរកឃើញថាមានជំងឺប្រកាច់ ដែលបញ្ហានេះកើតឡើងលើកុមារអូទីស្សឹមច្រើនជាងកុមារទូទៅ។ នាងបានព្យាបាលដោយថ្នាំពេទ្យ។ ក្រោយពេលព្យាបាល **រំដួល**ឈប់មានប្រកាច់ និងគេងលក់ស្រួលឡើងវិញ ព្រមទាំងអាចចូលរៀនក្នុងថ្នាក់បានវិញធម្មតាផងដែរ។

2.Flashcard_Level2_Khmer_V6.indd 28 9/6/23 2:41 PM

# ព័ត៌មានបន្ថែម៖

- **ភាពមិនប្រក្រតីនៃដំណើរការញ្ញាណដឹង:** កុមារអូទីស្សឹមអាចរងឥទ្ធិពលពីញ្ញាណដឹងផ្សេងៗ ដូចជា ការប៉ះ រសជាតិ ក្លិន ការមើលឃើញ សំឡេង និងចលនាជាដើម។ រឿងនេះច្រើនកើតមានក្នុងចំណោមកុមារមត្តេយ្យសិក្សា។ ពួកគេបានយកជម្នះឥទ្ធិពលញ្ញាណដឹងទាំងនេះ បន្តិចម្តងៗ នៅពេលដែលពួកគេចម្រើនវ័យ។
- **បញ្ហាការគេង:** កុមារអូទីស្សឹម ជាពិសេសកុមារទើបចេះដើរតេះតះ (ក្រោម 5 ឆ្នាំ) អាចមានការពិបាកដេក គេងមិនលក់ ឬគេងមិនគ្រប់គ្រាន់។ ការអនុវត្តអនាម័យមុនចូលគេង និងការជៀសវាងឧបករណ៍អេឡិចត្រូនិកមុនពេលចូលគេង អាចធ្វើឲ្យការគេងរបស់កុមារបានល្អប្រសើរឡើងវិញ។
- **បញ្ហាក្រពះពោះវៀន:** កុមារអូទីស្សឹម ជៀសវាងការទទួលទានអាហារច្រើនមុខ ដោយសារបញ្ហាញ្ញាណដឹង ហើយអាចទទួលរងពីកង្វះអាហារូបត្ថម្ភ និងកង្វះវីតាមីន។ អ្នកព្យាបាលមុខងារប្រចាំថ្ងៃ អាចវាយតម្លៃ និងណែនាំនូវអាហារប្រភេទផ្សេងៗបន្តិចម្តងៗ ដោយប្រឹក្សាជាមួយឪពុកម្តាយ។
- **ពិការភាពបញ្ញា:** កុមារពី 6 ទៅ 7 នាក់ក្នុងចំណោម 10 នាក់ដែលមានអូទីស្សឹមអាចមានបញ្ហាការយល់ដឹង ដូច្នេះហើយ ប៉ះពាល់ដល់ការសិក្សារបស់ពួកគេ។ ទោះយ៉ាងណាក៏ដោយ មានតែ 2 នាក់ក្នុងចំណោម 10 នាក់ប៉ុណ្ណោះ ដែលត្រូវការការអប់រំពិសេស ហើយក្រៅពីនេះ កុមារអាចទៅសាលារៀន ធម្មតាបាន ប្រសិនបើពួកគេមានការគាំទ្រគ្រប់គ្រាន់។

*ប្រសិនបើអ្នកគិតថា កូនរបស់អ្នកអាចមានបញ្ហារួមផ្សំផ្សេងៗ សូមពិភាក្សាជាមួយអ្នកចិត្តវិទ្យា និងគ្រូបង្រៀន។*
*លើសពីនេះ គ្រូពេទ្យ ឬអ្នកជំនាញ អាចវាយតម្លៃកូនរបស់អ្នក និងបង្កើតផែនការព្យាបាលផងដែរ។*

សហការផលិតដោយ

ក្រោមជំនួយឧបត្ថម្ភពី រដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធី ACCESS

# បណ្ណលេខ៨(ក):កិច្ចសហការរវាងវិស័យអប់រំ វិស័យសុខាភិបាល និងមាតាបិតា



មន្ទីរពេទ្យ



សាលារៀន





មណ្ឌលថែទាំសុខភាពផ្លូវចិត្ត



គ្រួសារ

កាលនៅមត្តេយ្យ **រំដួល**មានបញ្ហាក្នុងផ្ចង់អារម្មណ៍ មិនអង្គុយនៅមួយកន្លែង (រពឹស) ហើយមិនចាប់អារម្មណ៍នឹងប្រដាប់លេង។ ពេលនៅសាលារៀន នាងធ្លាប់បានកើតជំងឺប្រកាច់ ដែលនាងត្រូវបានព្យាបាលដោយថ្នាំពេទ្យជាប្រចាំ។ គ្រូរបស់នាង និងអ្នកចិត្តវិទ្យាបានសហការគ្នាព្យាបាល និងអប់រំដល់នាង។ ឳពុកម្តាយរបស់**រំដួល** បានរក្សាទំនាក់ទំនងជាមួយពួកគេជានិច្ច និងស្វែងរកជំនួយទាន់ពេលវេលា ពេលណាពួកគាត់ត្រូវការជំនួយនៅផ្ទះ។

# ព័ត៌មានបន្ថែម៖

សុភាសិតមួយពោលថា៖ **«ត្រូវការមនុស្សមួយភូមិដើម្បីចិញ្ចឹមកុមារម្នាក់»** នេះគូសបញ្ជាក់ថា កុមារត្រូវការមនុស្សនៅជុំវិញរួមគ្នាផ្តល់ឱកាសឲ្យកុមារអភិវឌ្ឍន៍ ។ កិច្ចសហការគ្នា អាចជួយឲ្យកុមារអូទីស្សឹមមានឱកាសរៀនសូត្រ និងអភិវឌ្ឍដូចកុមារដទៃដែរ។ តាមរយៈការធ្វើការរួមគ្នា រវាងវិស័យអប់រំ វិស័យសុខាភិបាល និងមាតាបិតា អាចផ្តល់ជំនួយដល់កុមារ ដែលពួកគេត្រូវការ ដើម្បីឈានទៅដល់សក្តានុពលពេញលេញរបស់ពួកគេ។ មនុស្សទាំងបីក្រុមនេះ ត្រូវតែធ្វើការរួមគ្នា ដើម្បីស្វែងរកអ្វីដែលមានប្រសិទ្ធភាពបំផុតសម្រាប់កុមារ។

ខាងក្រោមនេះ ជាឧទាហរណ៍មួយចំនួន អំពីរបៀបដែលវិស័យអប់រំ វិស័យសុខាភិបាល និងឪពុកម្តាយអាចសហការគ្នា ដើម្បីគាំទ្រកុមារអូទីស្សឹម៖

- កុមារដែលមានអូទីស្សឹម (ក្រោម 6 ឆ្នាំ) មានបញ្ហាប្រឈមផ្នែកសុខភាពជាច្រើន ហើយត្រូវការអ្នកជំនាញផ្នែកសុខភាព ដើម្បីគាំទ្រឪពុកម្តាយក្នុងការគ្រប់គ្រងបញ្ហាដំណេក អារម្មណ៍ឆេវឆាវ បញ្ហាការផ្ទង់អារម្មណ៍ និងបញ្ហាញាណដឹង និងបញ្ហាផ្សេងៗទៀត។ អ្នកជំនាញផ្នែកសុខភាពអាចផ្តល់ការអប់រំផ្លូវចិត្ត ណែនាំឪពុកម្តាយអំពីយុទ្ធសាស្ត្រ និងឱសថនៅផ្ទះនៅពេលចាំបាច់។
- គ្រូបង្រៀនអាចបង្កើតផែនការអប់រំជាលក្ខណៈបុគ្គល (IEP) ដើម្បីបំពេញតាមតម្រូវការផ្ទាល់ខ្លួនរបស់កុមារ និងប្រឹក្សាជាមួយឪពុកម្តាយ។

សហការផលិតដោយ

ក្រោមជំនួយឧបត្ថម្ភពី រដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធី ACCESS

Australian Aid

ACCESS Sustainable quality services for all

2.Flashcard_Level2_Khmer_V6.indd 31 9/6/23 2:41 PM

# បណ្ណលេខ៨(ខ):កិច្ចសហការវាងវិស័យអប់រំ វិស័យសុខាភិបាល និងមាតាបិតា



ជួយពីអ្នកព្យាបាល



ជួយពីគ្រូពេទ្យ



ជួយពីគ្រូបង្រៀន



ជួយពីឪពុកម្ដាយ

**រំដួល**អាចប្រាស្រ័យទាក់ទង និងឆ្លើយឆ្លងជាមួយអ្នកដទៃ ព្រមទាំងអាចរាប់អានមិត្តភក្តិនៅសាលាបានជាធម្មតា។ ដោយមានកិច្ចសហការ និងការគាំទ្រយ៉ាងជិតស្និទ្ធពីវិស័យអប់រំ និងសុខាភិបាល ព្រមទាំងឪពុកម្ដាយផង ទើបធ្វើឲ្យនាងឈានដល់សក្ដានុពលពេញរបស់នាង។

# ព័ត៌មានបន្ថែម៖

- នៅពេលដែលកុមារអូទីស្សឹម អាចសុំជាមួយនឹងបរិយាកាសសាលារៀនហើយ គ្រូអាចណែនាំផ្តល់ការអប់រំពិសេស។ កុមារខ្លះអាចចូលសាលារៀនពិសេសមួយ ឬពីរថ្ងៃក្នុងមួយសប្តាហ៍ ហើយនៅសល់ពួកគេអាចទៅសាលារៀនធម្មតាវិញ ប៉ុន្តែកុមារខ្លះ អាចត្រូវការការអប់រំពិសេសពេញម៉ោង។
- ឳពុកម្តាយគួរតែសហការយ៉ាងសកម្មជាមួយអ្នកចិត្តវិទ្យា និងគ្រូបង្រៀន ដើម្បីបំពេញតម្រូវការកូនខ្លួន បន្ថែមពីលើការផ្តល់សេចក្តីស្រឡាញ់ ការគាំទ្រ និងការយល់ដឹងដល់កូន។

មាតាបិតាអាចតស៊ូមតិ ដើម្បីទាមទារនូវសិទ្ធិ និងតម្រូវការរបស់កុមារ មិនត្រឹមតែកូនរបស់ខ្លួន ប៉ុណ្ណោះទេ ប៉ុន្តែសម្រាប់កុមារអូទីស្សឹមទាំងអស់ផងដែរ តាមរយៈថ្ងៃអន្តរជាតិដូចជាទិវាអូទីស៊ីមពិភពលោក (ថ្ងៃទី 2 ខែមេសា) និង ក្រុមប្រឹក្សាសកម្មភាពជនពិការ (DAC) ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា (MoSVY) ។

*តាមរយៈការធ្វើការរួមគ្នា រវាងវិស័យអប់រំ វិស័យសុខាភិបាល និងឳពុកម្តាយ អាចធ្វើឱ្យមានការផ្លាស់ប្តូរវិជ្ជមាននៅក្នុងជីវិតរបស់កុមារ អូទីស្សឹម។ ទាំងអស់គ្នាអាចជួយកុមារទាំងនេះឱ្យឈានដល់សក្តានុពលពេញលេញរបស់ពួកគេ និងរស់នៅប្រកបដោយសុភមង្គលបំពេញមួយជីវិត។*

សហការផលិតដោយ

ក្រោមជំនួយឧបត្ថម្ភពី រដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធី ACCESS

2.Flashcard_Level2_Khmer_V6.indd 33 9/6/23 2:41 PM

# របៀបប្រើបណ្ណ(ប្រធានបទទី២) ស្ដីពីការស្វែងយល់អំពីកុមារអូទីស្សឹម នៅសាលារៀន

**១). តើបណ្ណទាំងនេះនិយាយអំពីអ្វីខ្លះ (សារៈសំខាន់ៗ)៖**

ប័ណ្ណទាំងអស់នេះពន្យល់ពីបញ្ហាប្រឈម និងឱកាសសម្រាប់កុមារអូទីស្សឹម តួនាទីរបស់គ្រូបង្រៀន និងឪពុកម្ដាយក្នុងការជួយកូនរបស់ពួកគេ រួមទាំងការអន្តរាគមន៍នៅផ្ទះ។

**២). តើអ្នកណាខ្លះ នឹងទទួលបានអត្ថប្រយោជន៍ពីបណ្ណទាំងនេះ (ក្រុមគោលដៅ)៖**

- មាតាបិតា គ្រូបង្រៀន បុគ្គលិកថែទាំសុខភាពបឋម អ្នកធ្វើថែទាំសុខភាពសហគមន៍ មេភូមិ និងឃុំ។

**៣). ការជូនដំណឹង និងការរៀបចំការផ្សព្វផ្សាយ (ការផ្សព្វផ្សាយនៅក្នុងសហគមន៍)៖**

- សូមជ្រើសរើសកន្លែងស្ងាត់ ប្រាប់អ្នកចូលរួមអំពីទីតាំង និងគោលបំណងនៃការប្រជុំ ។ សូមឲ្យឪពុកម្ដាយ ដែលមានកូនអូទីស្សឹមដែលចូលរៀននៅសាលាចូលរួមនៅការពិភាក្សា (ធ្វើជាអ្នកដឹកនាំមិត្ត)។ សូមជូនដំណឹងដល់មេភូមិ និងឃុំអំពីគោលបំណង និងសុំអនុញ្ញាតិសម្រាប់ការជួបជុំនេះ។

**៤). របៀបប្រើបណ្ណទាំងនេះ (ដំណើរការប្រាស្រ័យទាក់ទងដើម្បីផ្លាស់ប្ដូរការប្រព្រឹត្ត)៖**

- គួរមានអ្នកចូលរួមចន្លោះពី១០ទៅ១៥នាក់ គឺជាការល្អបំផុត។
- ប្រសិនបើមានអ្នកចូលរួមច្រើន សូមប្រើប័ណ្ណពីរឈុតជាការល្អ។
- ចែកប័ណ្ណឲ្យអ្នកចូលរួមម្នាក់១សន្លឹក។
- ទុកពេលឲ្យពួកគាត់អាន និងពិនិត្យមើលរូបភាពដោយខ្លួនឯងសិន មុននឹងចាប់ផ្ដើមពិភាក្សា។

**៥). ប្រធាននៅក្នុងឈុតបណ្ណកម្រិត២ (មាតិកា)៖**

- **ប័ណ្ណលេខ១:** ការលើកកម្ពស់សកម្មភាពនៃការរស់នៅប្រចាំថ្ងៃ (ADL) ក្នុងការរៀបចំខ្លួនទៅសាលារៀន។

- **បណ្ណលេខ២:** របៀបរៀន (ភាលវិភាគដោយប្រើរូបភាព)។
- **បណ្ណលេខ៣:** ផែនការអប់រំបុគ្គល (IEP)។
- **បណ្ណលេខ៤:** សារៈសំខាន់នៃការចូលរួម និងការគាំទ្ររបស់មាតាបិតាក្នុងការងារសាលា។
- **បណ្ណលេខ៥:** ការលើកកម្ពស់ទំនាក់ទំនងសង្គម។
- **បណ្ណលេខ៦:** បញ្ហាអាកប្បកិរិយាក្នុងថ្នាក់រៀន។
- **បណ្ណលេខ៧:** ប្រភេទបញ្ហារួមផ្សំផ្សេងៗ។
- **បណ្ណលេខ៨:** កិច្ចសហការគ្នាល្អរវាងវិស័យអប់រំ វិស័យសុខាភិបាល និងមាតាបិតា។

**៦). របៀបដឹកនាំការពិភាក្សា សង្ខេប និងបញ្ចប់ការពិភាក្សា (គោលការណ៍រៀនសូត្រតាមបែបចូលរួម)៖**

- សូមសួរអ្នកចូលរួមថា តើពួកគេអានពិនិត្យមើល និងអានប័ណ្ណដែលទទួលបាននោះចប់ហើយ ឬនៅ ឬត្រូវការពេលវេលាបន្ថែមទៀត។
- ពេលអ្នកចូលរួមម្នាក់ៗអានប័ណ្ណនេះចប់ហើយ សូមឲ្យពួកគាត់ចែករំលែកនូវរឿងរ៉ាវនៅលើប័ណ្ណផ្នែកខាងមុខ ដោយចាប់ផ្តើមពីអ្នកមានប័ណ្ណលេខមុនគេ។
- រួចហើយអ្នកសម្របសម្រួលចាប់ផ្តើមផ្តល់ព័ត៌មានបន្ថែមសម្រាប់បណ្ណនីមួយៗ (នៅផ្នែកខាងក្រោយ)
- សូមផ្តល់ឱកាសឲ្យមានការពិភាក្សាគ្នា ដូចជា ស្វែងយល់ បកស្រាយបញ្ជាក់បញ្ហាផ្សេងៗ មុននឹងចូលទៅបណ្ណបន្ទាប់ទៀត។
- សូមស្នើសុំឲ្យអ្នកចូលរួមណាម្នាក់ស្ម័គ្រចិត្តសង្ខេបនូវអ្វីដែលបានពិភាក្សាគ្នា។
- អ្នកសម្របសម្រួលឆ្លើយសំណួរ ផ្តល់ការបំភ្លឺ និងគូសបញ្ជាក់សារៈសំខាន់ៗ
- មុនបញ្ចប់ការពិភាក្សា សូមធ្វើសេចក្តីសន្និដ្ឋានលើប្រធានបទ ប្រាប់ពីពេលវេលាសម្រាប់ការណាត់ជួបប្រជុំគ្នាលើក្រោយទៀត

សហការផលិតដោយ

ក្រោមជំនួយឧបត្ថម្ភពី រដ្ឋាភិបាលអូស្ត្រាលី តាមរយៈកម្មវិធី ACCESS

Australian Aid

ACCESS Sustainable quality services for all

# សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង

## អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាសកម្មភាពជនពិការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

អគារលេខ៧៨៨ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ

+៨៥៥-២៣-៧២៧-៤២៨

+៨៥៥-២៣-៧២៧-៤២៦

info@dac.org.kh

www.dac.org.kh

ក្រុមប្រឹក្សាសកម្មភាពជនពិការ-Disability Action Council

## មជ្ឈមណ្ឌលសុខភាពផ្លូវចិត្តកុមារ និងយុវជន (ការីតាស ម.ស.ផ.ក)

មន្ទីរពេទ្យបង្អែកជ័យជំនះ តាខ្មៅ ខេត្តកណ្ដាល

+៨៥៥-២៣-៩៨៣-៣៤៨

+៨៥៥-៩២-៨៩៥-៤៦៦

ccamh-admin@caritascambodia.org

caritascambodia.org

www.CCAMH Cambodia



2.Flashcard_Level2_Khmer_V6.indd 37 9/6/23 2:41 PM